ធនាគារជាតិ នៃ កម្ពុជា
ប្រាក់រៀល. ស្ថិរភាព. អភិវឌ្ឍន៍.

# ព្រឹត្តិបត្រប្រចាំត្រីមាស

លេខ៦៧
ត្រីមាសទី២ ឆ្នាំ២០២១



ចេញផ្សាយតាមប្រកាសលេខ
៨៦-០១១-១២៣ ប្រ.ក
ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១១

## បោះពុម្ពផ្សាយដោយ

# ធនាគារជាតិ នៃ កម្ពុជា


| | | |
|---|---|---|
| អាសយដ្ឋាន | : | ឡូត៍លេខ៨៨ ផ្លូវលេខ១០២ កែងនឹងផ្លូវលេខ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| ប្រអប់សំបុត្រ | : | ២៥ |
| ទូរស័ព្ទ | : | (៨៥៥) ២៣ ៧២២ ៥៦៣ |
| ទូរសារ | : | (៨៥៥) ២៣ ៤២៦ ១១៧ |
| គេហទំព័រ | : | www.nbc.org.kh |


*********

## Published by

# National Bank of Cambodia


| | | |
|---|---|---|
| Address | : | #88 Street 102 Corner Street 19, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, Cambodia. |
| P.O.BOX | : | 25 |
| Phone | : | (855) 23 722 563 |
| FAX | : | (855) 23 426 117 |
| Website | : | www.nbc.org.kh |



**គណៈកម្មការព្រឹត្តិបត្រ**

- ឯកឧត្តម ថា យ៉ាវ ប្រធាន
- ឯកឧត្តម ស៊ុំ សន្និសិទ្ធ និពន្ធនាយក

**Review Commission**

| | |
|---|---|
| H.E. Tha Yao | Chairman |
| H.E. Dr. Sum Sannisith | Chief Editor |

# អារម្ភកថា



## ឯកឧត្តម ជា ចាន់តូ
## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

**ប្រិយមិត្តអ្នកអានជាទីមេត្រី!**

ធនាគារជាតិនៃកម្ពុជាមានកិត្តិយសសូមផ្សព្វផ្សាយព្រឹត្តិបត្រប្រចាំត្រីមាសទី២ ឆ្នាំ២០២១ ដោយរួមបញ្ចូលនូវព័ត៌មានសំខាន់ៗ ដូចជា៖ i/-ស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធធនាគារ ii/-បទប្បញ្ញត្តិថ្មីៗនិង iii/-សេចក្តីប្រកាសព័ត៌មាន ជាដើម។ ព័ត៌មានទាំងនេះក៏នឹងផ្តល់ជាធាតុចូលដល់ប្រិយមិត្តអ្នកអានទាំងអស់ក្នុងការបង្កើនចំណេះដឹងផ្នែកសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ដូចជាគាំទ្រដល់ការសម្រេចចិត្តលើនយោបាយពាក់ព័ន្ធផ្សេងៗ។

កាលពីខែកក្កដាកន្លងទៅនេះ មូលនិធិរូបិយវត្ថុអន្តរជាតិបានរក្សាការព្យាករកំណើនសេដ្ឋកិច្ចពិភពលោកសម្រាប់ឆ្នាំ២០២១ ដែលបានធ្វើឡើងកាលពីខែមេសា នៅក្នុងអត្រា ៦% ដដែល ប៉ុន្តែបានដំឡើងកំណើនសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍ពី ៥,១% ដល់ ៥,៦% និងបន្ទាបកំណើនសេដ្ឋកិច្ចប្រទេសកំពុងលូតលាស់និងកំពុងអភិវឌ្ឍន៍ ពី ៦,៧ មកនៅត្រឹម ៦,៣%។ ក្នុងនោះកំណើនសេដ្ឋកិច្ចប្រទេសអាស៊ាន-៥រួមមានឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន ថៃ និងវៀតណាម ត្រូវបានបន្ទាបពី ៤,៩% មកត្រឹម ៤,៣% និងឥណ្ឌាពី ១២,៥% មកត្រឹម ៩,៥% ដោយសារជួបប្រទះនឹងរលកថ្មីនៃវិបត្តិជំងឺកូវីដ-១៩។

សម្រាប់កម្ពុជា រាជរដ្ឋាភិបាលបានធ្វើបច្ចុប្បន្នកម្មកំណើនសេដ្ឋកិច្ចដោយបន្ថយពី ៤% មក ២,៤% ដោយសារឥទ្ធិពលនៃការអូសបន្លាយការរីករាលដាលជំងឺកូវីដ-១៩ ក្នុងសហគមន៍ទៅលើវិស័យចម្បងៗនៃសេដ្ឋកិច្ច។ ទោះយ៉ាងណា កម្ពុជារក្សាបានអត្រាអតិផរណាទាបជាមធ្យម ២,៨% នៅត្រីមាសទី២។ អតិផរណានេះបណ្តាលមកពីការងើបឡើងវិញនៃថ្លៃក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ ខណៈកំណើនថ្លៃម្ហូបអាហារបានថយល្បឿនហើយអតិផរណាស្នូលបន្តមានស្ថិរភាព។ ចំណែកឯអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកជាមធ្យមមានកម្រិត ៤.០៩៣ រៀល ដោយប្រាក់រៀលបានឡើងថ្លៃបន្តិច ០,២%ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន។

ទោះបីជាមានផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ-១៩ក៏ដោយ វិស័យធនាគារនៅកម្ពុជាបន្តមានភាពធន់ ដោយសារការដាក់ចេញនូវវិធានការម៉ាក្រូនិងមីក្រូប្រុងប្រយ័ត្នប្រកបដោយប្រសិទ្ធភាព។ លើសពីនេះ ក្នុងស្ថានភាពមិនច្បាស់លាស់នៃការរីករាលដាលនៃជំងឺកូវីដ-១៩ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវវិធានការអនុគ្រោះជាបន្តបន្ទាប់ ដើម្បីចូលរួមគាំទ្រសកម្មភាពសេដ្ឋកិច្ច ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ធនាគារជាតិនៃកម្ពុជាក៏បន្តលើកទឹកចិត្តការប្រើប្រាស់ការទូទាត់អេឡិចត្រូនិកដែលបច្ចុប្បន្ន មានកាន់តែសំបូរបែប សុវត្ថិភាពខ្ពស់ សេវាឆាប់រហ័ស និងតម្លៃសមរម្យ។ ការប្រើប្រាស់សេវាទូទាត់អេឡិចត្រូនិក ដែលមានដូចជាកម្មវិធីបាគង ដែលជាប្រព័ន្ធទូទាត់បែបទំនើបថ្មីមួយ និងសេវាធនាគារតាមកម្មវិធីទូរស័ព្ទចល័ត ជាដើម បានរួមចំណែកយ៉ាងច្រើនក្នុងការកាត់បន្ថយចំណាយប្រតិបត្តិការ ព្រមទាំងជួយបង្ការការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ទៀតផង។

### ប្រិយមិត្តអ្នកអានជាទីមេត្រី!

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា ដែលបាននិងកំពុងបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ព្រមទាំងក្រសួង-ស្ថាប័ន រាជរដ្ឋាភិបាល គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធទាំងអស់ ដែលបានរួមចំណែកអភិវឌ្ឍវិស័យធនាគារកម្ពុជាឱ្យមានការរីកចម្រើនជាលំដាប់ និងបោះជំហានទៅមុខយ៉ាងស្វាហាប់ ដើម្បីជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយភាពរឹងមាំ ចីរភាព និងបរិយាបន្ន។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រិយមិត្តអ្នកអានទាំងអស់ សូមជួបប្រទះនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

### សូមអរគុណ!

ឧឧឧ*ឆឆឆ

# មាតិកា


អារម្ភកថា ........................................................................................................ i-ii

**ផ្នែកទី១: សេចក្តីប្រកាសព័ត៌មាន**

១.១. សេចក្តីជូនដំណឹងស្តីពី ការលើកទឹកចិត្តឱ្យប្រើប្រាស់សេវាអេឡិចត្រូនិក ........................ ១

១.២. សេចក្តីប្រកាសព័ត៌មាន ការចុះអនុស្សរណៈយោគយល់ស្តីពី កិច្ចសហប្រតិបត្តិការក្នុងការចែករំលែកព័ត៌មាននិងចំណេះដឹងផ្នែកបច្ចេកវិទ្យា និងនវានុវត្តន៍រវាងធនាគារជាតិនៃកម្ពុជា និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍........................................................... ២

១.៣. សេចក្តីជូនដំណឹងស្តីពី វិធានការអនុគ្រោះដំណាក់កាលទី៣ របស់ធនាគារជាតិនៃកម្ពុជា .... ៣

១.៤. ធនាគារជាតិនៃកម្ពុជាបានចេញផ្សាយរបាយការណ៍ឆ្នាំ២០២០ស្តីពី ប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា....................................................................................... ៤

១.៥. ធនាគារជាតិនៃកម្ពុជាបានបោះផ្សាយសៀវភៅរបាយការណ៍ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុប្រចាំឆ្នាំ២០២០ ....................................................................................... ៥

**ផ្នែកទី២: កម្រងរូបថត**

២.១. ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានទទួលជួបសម្តែងការគួរសម និងពិភាក្សាការងារតាមប្រព័ន្ធអនឡាញជាមួយឯកអគ្គរដ្ឋទូតថ្មីនៃ ប្រទេសសិង្ហបុរីប្រចាំកម្ពុជា ៦

២.២. ធនាគារជាតិនៃកម្ពុជា បានរៀបចំការប្រឡងលើកទី៣៦ តាមប្រព័ន្ធអនឡាញ សម្រាប់វគ្គ FSI Connect ដោយមានការត្រួតពិនិត្យផ្ទាល់ដោយ ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អមដោយជំនាញការនៃធនាគារជាតិនៃកម្ពុជា .......................... ៧

២.៣. លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមកិច្ចប្រជុំជាមួយនាយកដ្ឋានរូបិយវត្ថុនិងទីផ្សារមូលធន របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ដើម្បីពិភាក្សាលើការអភិវឌ្ឍប្រព័ន្ធទូទាត់ ព្រមទាំងកម្មវិធីជំនួយបច្ចេកទេសរបស់ IMF ចំពោះធនាគារជាតិនៃកម្ពុជា....................................................................... ៨

២.៤. លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមកិច្ចប្រជុំជាមួយគណៈប្រតិភូនៃក្រុមប្រឹក្សាធុរកិច្ចអាមេរិក-អាស៊ាន (US-ABC)........... ៩

២.៥. លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមកិច្ចប្រជុំជាន់ខ្ពស់ ក្នុងអំឡុងកិច្ចប្រជុំនាទិយរដូវប្រចាំឆ្នាំ២០២១ របស់មូលនិធិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក តាមរយៈប្រព័ន្ធអនឡាញ .................................... ១០

២.៦. លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាយោបល់ក្នុងតំបន់អាស៊ី (FSB RCG Asia).................................. ១១

២.៧. លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមសិក្ខាសាលាតាមរយៈប្រព័ន្ធអនឡាញស្តីពី "ការត្រួតពិនិត្យផ្អែកលើហានិភ័យ Pillar 2" ១២
២.៨. លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានដឹកនាំមន្ត្រីជំនាញចូលរួមសិក្ខាសាលាស្តីពី "ទំនើបកម្មក្របខ័ណ្ឌគោលនយោបាយរូបិយវត្ថុប្រទេសកម្ពុជា ឡាវ និងវៀតណាម"........ ១៣
២.៩. លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានអនុញ្ញាតឱ្យនាយកការិយាល័យតំណាងពាណិជ្ជកម្មធនាគារ ស៊ូមីតូម៉ូ មីតស៊ុយ បែងឃីង ខបភើរេសិន ចូលជួបសម្តែងការគួរសម និងជម្រាបជូនពីស្ថានភាពនិងទិសដៅអនាគតរបស់ការិយាល័យតំណាង ១៤
២.១០. លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមក្នុងសន្និសីទជាន់ខ្ពស់តាមរយៈប្រព័ន្ធអនឡាញ ដែលសហការរៀបចំដោយ វិទ្យាស្ថានស្ថិរភាពហិរញ្ញវត្ថុ (FSI) ធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) និងធនាគារកណ្តាលនៃប្រទេសបាហាម៉ាស់ (Bahamas)........ ១៥
២.១១. លោកជំទាវ អ៊ុក ម៉ាលី ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំគណៈកម្មការគោលនយោបាយ (Policy Committee) ស្តីពីការអនុវត្តកម្មវិធីឆ្លើយតបនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ និងការស្តារសម្បទាសេដ្ឋកិច្ចឡើងវិញ........ ១៦
២.១២. លោកជំទាវ អ៊ុក ម៉ាលី ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមកិច្ចប្រជុំលើកទី១ គណៈកម្មាធិការជាតិជំរុញសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២១ ........ ១៧
២.១៣. ឯកឧត្តម ស៊ុំ សន្និសិទ្ធ ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមកិច្ចប្រជុំគោលនយោបាយអាស៊ានប្រចាំឆ្នាំ២០២១ ក្រោមប្រធានបទស្តីពី "បញ្ហាប្រឈម និងជម្រើសក្នុងការគ្រប់គ្រងលំហូរមូលធនសម្រាប់ប្រទេសដែលមានសេដ្ឋកិច្ចតូច បើកទូលាយ និងមានសមាហរណកម្មវិស័យហិរញ្ញវត្ថុ" ........ ១៨
២.១៤. ឯកឧត្តម ស៊ុំ សន្និសិទ្ធ ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមសិក្ខាសាលាស្តីពី ការប្រែប្រួលអាកាសធាតុ និងហានិភ័យអធិបតេយ្យភាព........ ១៩
២.១៥. ឯកឧត្តម ស៊ុំ សន្និសិទ្ធ ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ២០២១ លើកទី៩១ របស់ធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) តាមរយៈប្រព័ន្ធអនឡាញ........ ២០
២.១៦. ធនាគារជាតិនៃកម្ពុជាបានបើកយុទ្ធនាការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនដល់មន្ត្រីបុគ្គលិក, បុគ្គលិកកិច្ចសន្យា និងបុគ្គលិកអណ្តែតសរុបប្រមាណ ៨០០នាក់ នៅមន្ទីរពេទ្យកុមារ........ ២១
២.១៧. លោកជំទាវ ជា សិរី ឧបការីទេសាភិបាល និងជាអគ្គនាយកបច្ចេកទេស ធនាគារជាតិនៃកម្ពុជា បានអញ្ជើញជាវាគ្មិន ក្នុងកិច្ចពិភាក្សាចែករំលែកបទពិសោធន៍ពាក់ព័ន្ធនឹងប្រព័ន្ធបាគង ដែលជាប្រព័ន្ធទូទាត់សងប្រាក់ជំនាន់ថ្មីរបស់ប្រទេសកម្ពុជា........ ២២

២.១៨. លោកជំទាវ ជា សិរី ឧបការីទេសាភិបាល និងជាអគ្គនាយកបច្ចេកទេស ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមជាវាគ្មិនកិត្តិយសក្នុងកិច្ចពិភាក្សាស្តីពី "ហេដ្ឋារចនាសម្ព័ន្ធឌីជីថលគ្រឹះសម្រាប់សេដ្ឋកិច្ចឌីជីថលប្រកបដោយបរិយាបន្ន" ក្នុងកម្មវិធី SFF Green Shoots Series ២៣

២.១៩. លោកជំទាវ ជា សិរី ឧបការីទេសាភិបាលនិងជាអគ្គនាយកបច្ចេកទេស ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមប្រជុំតាមប្រព័ន្ធអនឡាញជាមួយក្រុមហ៊ុន Moody's........................... ២៤

២.២០. លោកជំទាវ ជា សិរី ឧបការីទេសាភិបាល និងជាអគ្គនាយកបច្ចេកទេស ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីចុះអនុស្សរណៈយោគយល់ APIX រវាងអង្គភាពបណ្ដាញនវានុវត្តហិរញ្ញវត្ថុអាស៊ាន និងសមាគមហិរញ្ញវត្ថុនិងបច្ចេកវិទ្យាកម្ពុជា .............. ២៥

២.២១. ធនាគារជាតិនៃកម្ពុជាបានរៀបចំពិធីចុះអនុស្សរណៈយោគយល់ស្តីពី កិច្ចសហប្រតិបត្តិការក្នុងការចែករំលែកព័ត៌មាន និងចំណេះដឹងផ្នែកបច្ចេកវិទ្យានិងនវានុវត្តន៍ រវាងធនាគារជាតិនៃកម្ពុជា និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ................................................ ២៦

២.២២. ធនាគារជាតិនៃកម្ពុជាសហការជាមួយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានរៀបចំសិក្ខាសាលាចែករំលែកចំណេះដឹងស្តីពី ការចែករំលែកព័ត៌មាន និងចំណេះដឹងផ្នែកបច្ចេកវិទ្យា Distributed Technology និង Blockchain........................................................... ២៧

២.២៣. ធនាគារជាតិនៃកម្ពុជាបានរៀបចំសិក្ខាសាលាតាមរយៈប្រព័ន្ធអនឡាញ ដែលសហការជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ស្តីពីឧបករណ៍ហិរញ្ញវត្ថុស្វប់រូបិយប័ណ្ណ (Foreign Currency SWAP)............................................................................................. ២៨

២.២៤. អគ្គនាយកដ្ឋានត្រួតពិនិត្យនៃធនាគារជាតិនៃកម្ពុជា បានសហការជាមួយក្រុមការងារប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មនៃអគ្គស្នងការដ្ឋាននគរបាលជាតិ រៀបចំកិច្ចប្រជុំតាមប្រព័ន្ធអនឡាញស្តីពី កិច្ចសហការរវាងអគ្គស្នងការដ្ឋាននគរបាលជាតិ និងមន្ត្រីប្រតិបត្តិតាមនៃគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ..................................................................... ២៩

## ផ្នែកទី៣: តារាង (ភាសាខ្មែរនិងអង់គ្លេស)

៣.១. តារាងអត្រាប្តូរប្រាក់ប្រចាំខែ ..................................................................................... ៣០

៣.២. ប្រាក់បញ្ញើនៅធនាគារទទួលប្រាក់បញ្ញើ និងបម្រែបម្រួលប្រចាំខែ................................. ៣២

៣.៣. ឥណទានផ្តល់ដោយធនាគារទទួលប្រាក់បញ្ញើតាមប្រភេទជំនួញ និងបម្រែបម្រួលប្រចាំខែ..... ៣៣

៣.៤. ការផ្តល់ឥណទានរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិងអង្គការមិនមែនរដ្ឋាភិបាល.................... ៣៥

៣.៥. ការផាត់ទាត់មូលប្បទានបត្រតាមរយៈសភាផាត់ទាត់ .................................................... ៣៦

៣.៦. ប្រព័ន្ធធនាគារកម្ពុជា............................................................................................. ៣៨

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.ធ.៦៣..០២១.២៧៥...ធ.ជ.ណ..

*ថ្ងៃ អង្គារ ៩កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៤*
*រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមេសា ឆ្នាំ២០២១*

## សេចក្តីជូនដំណឹង
## ស្តីពី ការលើកទឹកចិត្តឱ្យប្រើប្រាស់សេវាអេឡិចត្រូនិក

ដើម្បីចូលរួមបង្ការ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលកំពុងរាតត្បាតយ៉ាងធ្ងន់ធ្ងរនៅក្នុងសហគមន៍ ធនាគារជាតិនៃកម្ពុជានឹងបន្តអនុវត្តវិធានការការពារហានិភ័យដែលអាចកើតឡើងជាយថាហេតុដោយសារការប្រើប្រាស់ក្រដាសប្រាក់ តាមរយៈការសម្លាប់មេរោគនៅលើក្រដាសប្រាក់រៀលដែលចូលមកធនាគារជាតិនៃកម្ពុជា ហើយបញ្ចេញក្រដាសប្រាក់ដែលសម្លាប់មេរោគរួចទៅក្នុងទីផ្សារវិញ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាក៏សូមបន្តលើកទឹកចិត្តក្នុងការកាត់បន្ថយការប្រើប្រាស់ក្រដាសប្រាក់ ក៏ដូចជាការប្រើប្រាស់/ចេញផ្សាយមូលប្បទានប័ត្រ សម្រាប់ធ្វើការផាត់ទាត់និងទូទាត់នានា ហើយជំនួសវិញដោយការប្រើប្រាស់ការទូទាត់អេឡិចត្រូនិកតាមលទ្ធភាពដែលអាចធ្វើទៅបាន។ ការប្រើប្រាស់សេវាទូទាត់អេឡិចត្រូនិក ដូចជាសេវាធនាគារតាមកម្មវិធីទូរស័ព្ទចល័ត ក៏ដូចជាកម្មវិធីបាគងដែលជាប្រព័ន្ធទូទាត់បែបទំនើបថ្មីមួយ នឹងផ្តល់សុវត្ថិភាពខ្ពស់ ភាពងាយស្រួល ឆាប់រហ័ស និងចំណាយតិចផងដែរ។

ធនាគារជាតិនៃកម្ពុជាសង្ឃឹមថា សាធារណជនទាំងអស់នឹងចូលរួមសហការកាត់បន្ថយហានិភ័យទាំងអស់គ្នា ជាពិសេសតាមរយៈការប្រើប្រាស់មធ្យោបាយទូទាត់អេឡិចត្រូនិកទំនើបៗនិងសម្បូរបែប ដែលមាននាពេលបច្ចុប្បន្ន និងសូមអនុវត្តនូវវិធានការ ៣ ការពារ ៣ កុំ និងការណែនាំនានារបស់ក្រសួងសុខាភិបាលឱ្យបានខ្ជាប់ខ្ជួន។

**សូមទំនាក់ទំនង៖**
ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ៖ (៨៥៥) ២៣ ៩៩០ ១៩៦
អ៊ីម៉ែល៖ nbccommunication@nbc.org.kh

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ.២៤.០២១.០០៥ ឈកស.ព័ត៌មាន

ថ្ងៃ ព្រហស្បតិ៍ ៣រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២១

# សេចក្តីប្រកាសព័ត៌មាន
## ការចុះអនុស្សរណៈយោគយល់ស្តីពី កិច្ចសហប្រតិបត្តិការក្នុងការចែករំលែកព័ត៌មាននិងចំណេះដឹងផ្នែកបច្ចេកវិទ្យា និងនវានុវត្តន៍ រវាងធនាគារជាតិនៃកម្ពុជា និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

នៅថ្ងៃព្រហស្បតិ៍ ៣រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៩ ខែមេសា ឆ្នាំ ២០២១ ធនាគារជាតិនៃកម្ពុជា និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍បានចុះអនុស្សរណៈយោគយល់ស្តីពី កិច្ចសហប្រតិបត្តិការក្នុងការចែករំលែកព័ត៌មាននិងចំណេះដឹងផ្នែកបច្ចេកវិទ្យា និងនវានុវត្តន៍ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីពាក់ព័ន្ធនៃស្ថាប័នទាំងពីរ។

ការចុះអនុស្សរណៈយោគយល់នេះប្រព្រឹត្តទៅក្នុងគោលបំណងលើកកម្ពស់ការចែករំលែកព័ត៌មាន និងចំណេះដឹងពាក់ព័ន្ធនឹងបច្ចេកវិទ្យា និងនវានុវត្តន៍ រវាងធនាគារជាតិនៃកម្ពុជា និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ឱ្យកាន់តែមានភាពងាយស្រួល និងប្រសិទ្ធភាព។ ស្របពេលជាមួយគ្នានេះ អនុស្សរណៈ-យោគយល់នេះជាសក្ខីភាពមួយដ៏សំខាន់ក្នុងការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការរវាងស្ថាប័នទាំងពីរ ក៏ដូចជាចូលរួមចំណែកក្នុងការជំរុញនវានុវត្តន៍ និងការប្រើប្រាស់សេវាធនាគារអនឡាញប្រកបដោយនិរន្តរភាព ចីរភាព សុវត្ថិភាព និងបរិយាបន្ន ដើម្បីគាំទ្រគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចឌីជីថលស្របតាមគោលដៅរបស់រដ្ឋាភិបាល។

លើសពីនេះ អនុស្សរណៈយោគយល់នេះក៏ជាថ្នាលសម្រាប់ពង្រឹងសមត្ថភាព និងចំណេះដឹងផ្នែកបច្ចេកវិទ្យា និងនវានុវត្តន៍សម្រាប់មន្ត្រីពាក់ព័ន្ធរបស់ស្ថាប័នទាំងពីរដូចមានចែងក្នុងខ្លឹមសារនៃអនុស្សរណៈយោគយល់ដើម្បីអនុវត្តការងារផ្សេងៗ ឱ្យកាន់តែមានប្រសិទ្ធភាពឆ្លើយតបទៅនឹងតម្រូវការ និងការរីកចម្រើននៃបច្ចេកវិទ្យានាពេលបច្ចុប្បន្ន។

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ៨៧.០២១.៣៩៥ ធ.ជ.ក

ថ្ងៃសុក្រ ១០កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១

## សេចក្តីជូនដំណឹង
## ស្តីពី
## វិធានការអនុគ្រោះដំណាក់កាលទី៣ របស់ធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជាមានកិត្តិយសសូមជម្រាបជូនសាធារណជនទូទៅ និងភាគីពាក់ព័ន្ធមេត្តាជ្រាបថា ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវវិធានការអនុគ្រោះជាបន្តបន្ទាប់ដើម្បីចូលរួមគាំទ្រគោលនយោបាយរាជរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាប្រឈមនិងសម្រាលបន្ទុកប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីជំងឺកូវីដ-១៩។ ក្នុងបរិការណ៍នៃការរីករាលដាលនៃជំងឺកូវីដ-១៩ ជាពិសេសព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ធនាគារជាតិនៃកម្ពុជាបានសម្រេចបន្តវិធានការអនុគ្រោះដំណាក់កាលទី៣ ដូចជា៖

- រក្សាការអនុវត្តប្រាក់បម្រុងកាតព្វកិច្ចតាមអត្រា ៧% ដដែលរហូតដល់មានការជូនដំណឹងជាថ្មីពីធនាគារជាតិនៃកម្ពុជា
- អនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបន្តធ្វើឥណទានរៀបចំឡើងវិញរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។ ចំពោះអតិថិជនដែលរស់នៅទីតាំងតំបន់បិទខ្ទប់តាមការកំណត់របស់រាជរដ្ឋាភិបាល ឬអាជ្ញាធរពាក់ព័ន្ធ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអាចធ្វើឥណទានរៀបចំឡើងវិញលើសពី ៣ដង ក្នុងអំឡុងពេលអនុគ្រោះនេះ និង
- បន្តលើកទឹកចិត្តឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុពិនិត្យលទ្ធភាពអនុគ្រោះ បន្ធូរបន្ថយឬលើកលែងការយកសោហ៊ុយ ឬការពិន័យផ្សេងៗតាមស្ថានភាពជាក់ស្តែងរបស់អតិថិជន។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនទូទៅនិងភាគីពាក់ព័ន្ធទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

## ធនាគារជាតិនៃកម្ពុជាបានចេញផ្សាយរបាយការណ៍ឆ្នាំ២០២០ស្តីពី ប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា

ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១

ប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជាមានការរីកចម្រើនយ៉ាងឆាប់រហ័ស ស្របតាមការវិវត្តនៃបច្ចេកវិទ្យាហិរញ្ញវត្ថុ និងបានរួមចំណែកយ៉ាងច្រើនក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ជាពិសេសគឺការទូទាត់ឌីជីថលក្នុងបរិបទនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ដើម្បីឆ្លុះបញ្ចាំងពីការរីកចម្រើននេះ ធនាគារជាតិនៃកម្ពុជាបានចេញផ្សាយរបាយការណ៍ឆ្នាំ២០២០ស្តីពី ប្រព័ន្ធទូទាត់សងប្រាក់នៅកម្ពុជា ដែលផ្តោតលើវឌ្ឍនភាពនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ សេវានិងឧបករណ៍ទូទាត់សងប្រាក់, ក្របខ័ណ្ឌបទប្បញ្ញត្តិនិងត្រួតពិនិត្យ បញ្ហាប្រឈម ព្រមទាំងទិសដៅអនាគត។ របាយការណ៍នេះជាឯកសារដ៏សំខាន់មួយសម្រាប់ការសិក្សាស្រាវជ្រាវ និងជាព័ត៌មានដល់ភាគីពាក់ព័ន្ធ ដើម្បីសិក្សាស្វែងយល់អំពីការអភិវឌ្ឍប្រព័ន្ធទូទាត់នៅកម្ពុជា។



## ធនាគារជាតិនៃកម្ពុជាបានបោះផ្សាយសៀវភៅរបាយការណ៍ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុប្រចាំឆ្នាំ២០២០

ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០២១




ឆ្នាំ២០២០ គឺជាឆ្នាំប្រកបដោយបញ្ហាប្រឈមដោយការរីករាលដាលនៃជំងឺកូវីដ-១៩ បានជះឥទ្ធិពលដល់សេដ្ឋកិច្ចនិងទីផ្សារហិរញ្ញវត្ថុពិភពលោក។ ដូចនឹងប្រទេសដទៃទៀតដែរ ប្រទេសកម្ពុជាត្រូវបានប៉ះពាល់ខ្លាំងដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩នេះ ដែលបានធ្វើឱ្យសេដ្ឋកិច្ចមានកំណើនអវិជ្ជមាន បន្ទាប់ពីសម្រេចបានកំណើនជាមធ្យមក្នុងរង្វង់ ៨ ភាគរយ ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ។ ទោះបីជាមានផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ-១៩ក៏ដោយ វិស័យធនាគារនៅកម្ពុជាបន្តមានភាពធន់ ដោយសារការដាក់ចេញនូវវិធានការ ម៉ាក្រូនិងមីក្រូប្រុងប្រយ័ត្នប្រកបដោយប្រសិទ្ធភាព។ ក្នុងស្ថានភាពមិនច្បាស់លាស់នេះដែរ ធនាគារជាតិនៃកម្ពុជាបន្តតាមដានជាប្រចាំនូវការវិវត្តថ្មីៗ និងត្រៀមខ្លួនដាក់ចេញវិធានការតាមការចាំបាច់ ដើម្បីបន្តរួមចំណែកគាំទ្រសកម្មភាពសេដ្ឋកិច្ច ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ធនាគារជាតិនៃកម្ពុជាមានសេចក្តីសោមនស្សរីករាយក្នុងការបោះផ្សាយសៀវភៅរបាយការណ៍ស្ថានភាពស្ថិរភាពហិរញ្ញវត្ថុប្រចាំឆ្នាំ២០២០ ដែលបង្ហាញពីការអភិវឌ្ឍនាពេលថ្មីៗនៅក្នុងវិស័យម៉ាក្រូសេដ្ឋកិច្ចនិងវិស័យហិរញ្ញវត្ថុ ព្រមទាំងបញ្ហាប្រឈម។ លើសពីនេះ សៀវភៅនេះពិភាក្សាអំពីទស្សនវិស័យនិងហានិភ័យនាពេលអនាគត ដែលវិស័យហិរញ្ញវត្ថុនឹងជួបប្រទះក្នុងអំឡុងពេលដែលមានភាពមិនច្បាស់លាស់នៃសេដ្ឋកិច្ចក្នុងស្រុក ក្នុងតំបន់ និងពិភពលោក ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩។ សៀវភៅនេះក៏នឹងត្រូវបានប្រើប្រាស់ជាឯកសារយោងសម្រាប់បុគ្គលបម្រើការនៅក្នុងវិស័យហិរញ្ញវត្ថុ បញ្ញវន្ត ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធ ដើម្បីស្វែងយល់ឱ្យបានកាន់តែច្បាស់អំពីស្ថានភាពស្ថិរភាពហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា។

## ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានទទួលជួបសម្តែងការគួរសមនិងពិភាក្សាការងារតាមប្រព័ន្ធអនឡាញជាមួយឯកអគ្គរដ្ឋទូតថ្មីនៃ ប្រទេសសិង្ហបុរីប្រចាំកម្ពុជា

ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១



កាលពីថ្ងៃអង្គារ ៥រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១ ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារ-ជាតិនៃកម្ពុជា បានទទួលជួបសម្តែងការគួរសម និង ពិភាក្សាការងារតាមប្រព័ន្ធអនឡាញ ជាមួយ លោកជំទាវ Teo Lay Cheng ឯកអគ្គរដ្ឋទូតថ្មីនៃ ប្រទេសសិង្ហបុរី ប្រចាំកម្ពុជា។ ឯកឧត្តម ទេសាភិបាល បានសម្តែងការ រីករាយនិងស្វាគមន៍ដែលលោកជំទាវ Teo Lay Cheng មកបំពេញទស្សនកិច្ច ក្នុងនាមជាឯកអគ្គរដ្ឋទូតនៃប្រទេសសិង្ហបុរីប្រចាំកម្ពុជា និងរំពឹងថា កិច្ចសហប្រតិបត្តិការ រវាងប្រទេសទាំងពីរ ជាពិសេសនៅក្នុងវិស័យធនាគារបន្តរីកចម្រើនទៅមុខទៀត ដើម្បីជួយគាំទ្រនិងរួមចំណែក អភិវឌ្ឍវិស័យហិរញ្ញវត្ថុនិងសេដ្ឋកិច្ចកម្ពុជា។ នាឱកាសនោះ ឯកឧត្តម ទេសា ភិបាល ក៏បានជម្រាបជូន លោកជំទាវ ឯកអគ្គរដ្ឋទូត ពីស្ថានភាពបច្ចុប្បន្ននៃសេដ្ឋកិច្ចកម្ពុជា និងបញ្ហាប្រឈមនានា ព្រមទាំងបានថ្លែង អំណរគុណចំពោះរដ្ឋាភិបាលសិង្ហបុរី និងអាជ្ញាធររូបិយវត្ថុសិង្ហបុរី ដែលកន្លងមក បានផ្តល់កិច្ចសហការ ជាមួយធនាគារជាតិនៃកម្ពុជាពាក់ព័ន្ធនឹងនវានុវត្តន៍ហិរញ្ញវត្ថុ (Financial Innovation) និងជួយធនាគារជាតិ នៃកម្ពុជាក្នុងការរៀបចំកម្មវិធីបច្ចេកវិទ្យាហិរញ្ញវត្ថុពិភពលោក ក្រោមរូបភាពជា Partner City នៃកម្មវិធី បច្ចេកវិទ្យាហិរញ្ញវត្ថុសិង្ហបុរី (Singapore FinTech Festival) ឆ្នាំ២០២០ ប្រកបដោយជោគជ័យ។ ទន្ទឹមនោះ លោកជំទាវ ឯកអគ្គរដ្ឋទូត បានថ្លែងអំណរគុណចំពោះធនាគារជាតិនៃកម្ពុជា ដែលតែងតែផ្តល់កិច្ចសហការ ល្អប្រសើរជាមួយអាជ្ញាធររូបិយវត្ថុសិង្ហបុរី ព្រមទាំងបានសម្តែងការអបអរសាទរចំពោះ ឯកឧត្តម ទេសាភិបាល ដែលត្រូវបានទស្សនាវដ្តីអន្តរជាតិដែលមានទីតាំងនៅប្រទេសអង់គ្លេសផ្តល់ ចំណាត់ថ្នាក់ជា ថ្នាក់ដឹកនាំ ធនាគារកណ្តាលឆ្នើម ឆ្នាំ២០២១ នៅតំបន់អាស៊ីប៉ាស៊ីហ្វិក ក្នុងចំណោមទេសាភិបាល ៥ រូបនៅលើពិភពលោក។ លោកជំទាវ ក៏បានកោតសរសើរនិងវាយតម្លៃខ្ពស់ចំពោះសមិទ្ធផល ដែលប្រព័ន្ធធនាគារកម្ពុជាសម្រេចបាន នាពេលកន្លងមក ក្រោមការដឹកនាំរបស់ឯកឧត្តម ទេសាភិបាល ដែលបានរួមចំណែកយ៉ាងសំខាន់នៅក្នុង ការគាំទ្រសកម្មភាពសេដ្ឋកិច្ច។ លោកជំទាវក៏បានបង្ហាញពីកិច្ច ខិតខំប្រឹងប្រែងបន្តទៀតក្នុងការពង្រឹងកិច្ចសហ-ប្រតិបត្តិការក្នុងវិស័យហិរញ្ញវត្ថុរបស់ប្រទេសទាំងពីរ និងបង្កលក្ខណៈឱ្យមានកិច្ចសហប្រតិបត្តិការកាន់តែ ទូលំទូលាយបន្ថែម ទៀត រវាងអាជ្ញាធររូបិយវត្ថុសិង្ហបុរី និងធនាគារជាតិនៃកម្ពុជា។





## ធនាគារជាតិនៃកម្ពុជា បានរៀបចំការប្រឡងលើកទី៣៦ តាមប្រព័ន្ធអនឡាញ សម្រាប់វគ្គ FSI Connect ដោយមានការត្រួតពិនិត្យផ្ទាល់ដោយ ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អមដោយជំនាញការនៃធនាគារជាតិនៃកម្ពុជា

ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១




នៅព្រឹកថ្ងៃអង្គារ ១៣រោច ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២១ ធនាគារជាតិនៃកម្ពុជា បានរៀបចំការប្រឡងលើកទី៣៦ តាមប្រព័ន្ធអនឡាញ សម្រាប់វគ្គ FSI Connect ដោយមានការត្រួតពិនិត្យផ្ទាល់ដោយ ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា អមដោយជំនាញការនៃធនាគារជាតិនៃកម្ពុជា។ សិក្ខាកាមចូលរួមក្នុងការប្រឡងនេះមានចំនួន ៧៦ រូប ដែលក្នុងនោះមានមន្ត្រីចំនួន ៣ រូប បានប្រឡងបញ្ចប់កម្រិតខ្ពស់ មន្ត្រីចំនួន ៧ រូប បានប្រឡងបញ្ចប់កម្រិតមធ្យម និង ៦ រូបបានប្រឡងបញ្ចប់កម្រិតបឋម។ វគ្គសិក្សាតាមប្រព័ន្ធអនឡាញនេះត្រូវបានរៀបចំឡើងដោយវិទ្យាស្ថានស្ថិរភាពហិរញ្ញវត្ថុអន្តរជាតិ នៃធនាគារសម្រាប់ការទូទាត់អន្តរជាតិ (Bank for International Settlement - BIS) ដែលមានស្នាក់ការកណ្តាលនៅប្រទេសស្វីស ហើយមានធនាគារកណ្តាល និងស្ថាប័នហិរញ្ញវត្ថុសាធារណៈជាង៣០០ នៅលើពិភពលោក។ គួរបញ្ជាក់ថា វគ្គសិក្សា NBC-FSI Connect ជាវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ ក្នុងកម្មវិធីអភិវឌ្ឍន៍សមត្ថភាពធនធានមនុស្ស ដែលត្រូវបានបង្កើតឡើងក្រោមការផ្តួចផ្តើមរបស់ឯកឧត្តម ជា ចាន់តូ ទេសាភិបាល ធនាគារជាតិនៃកម្ពុជា ក្នុងគោលបំណងធ្វើឯកទេសកម្មផ្នែកត្រួតពិនិត្យធនាគារ ដើម្បីឆ្លើយតបទៅតាមការប្រែប្រួលនៃនិម្មាបនកម្មហិរញ្ញវត្ថុនិងនិយាមអន្តរជាតិ ក៏ដូចជាសម័យកាលរីកចម្រើននៃប្រព័ន្ធធនាគារនាពេលបច្ចុប្បន្ន។





# លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមកិច្ចប្រជុំជាមួយនាយកដ្ឋានរូបិយវត្ថុនិងទីផ្សារមូលធន របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ដើម្បីពិភាក្សាលើការអភិវឌ្ឍប្រព័ន្ធទូទាត់ ព្រមទាំងកម្មវិធីជំនួយបច្ចេកទេសរបស់ IMF ចំពោះធនាគារជាតិនៃកម្ពុជា

ថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១




នៅព្រឹកថ្ងៃពុធ ១០រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១ លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានចូលរួមកិច្ចប្រជុំតាមរយៈប្រព័ន្ធអនឡាញ ជាមួយនាយកដ្ឋានរូបិយវត្ថុនិងទីផ្សារមូលធន របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ដើម្បីពិភាក្សាលើការអភិវឌ្ឍនប្រព័ន្ធទូទាត់ ព្រមទាំងកម្មវិធីជំនួយបច្ចេកទេសរបស់ IMF ចំពោះធនាគារជាតិនៃកម្ពុជា។ ចំពោះការអភិវឌ្ឍន៍ប្រព័ន្ធទូទាត់ លោកជំទាវ ទេសាភិបាលរង បានលើកឡើងអំពីការអភិវឌ្ឍប្រព័ន្ធបាគងដែលជាគំនិតផ្តួចផ្តើមថ្មីរបស់ធនាគារជាតិនៃកម្ពុជាក្នុងការធ្វើទំនើបកម្មប្រព័ន្ធទូទាត់នៅកម្ពុជាសំដៅលើកកម្ពស់ប្រតិបត្តិការរវាងធនាគារ សម្រួលការប្រើប្រាស់សាច់ប្រាក់រៀលក្នុងទីផ្សារ និងលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ។ មូលនិធិ-រូបិយវត្ថុអន្តរជាតិ បានកោតសរសើរចំពោះការធ្វើទំនើបកម្មនៃប្រព័ន្ធទូទាត់នេះ ព្រមទាំងបានលើកឡើងអំពីកម្មវិធីជំនួយបច្ចេកទេសដល់ធនាគារជាតិនៃកម្ពុជា ក្នុងការបន្តអភិវឌ្ឍប្រព័ន្ធទូទាត់ និងការពង្រឹងស្ថិរភាពហិរញ្ញវត្ថុនៅកម្ពុជា។ ឆ្លៀតក្នុងឱកាសនោះ លោកជំទាវ ក៏បានថ្លែងអំណរគុណចំពោះ មូលនិធិរូបិយវត្ថុអន្តរជាតិ ដែលបាននិងកំពុងផ្តល់ជំនួយបច្ចេកទេសដល់ធនាគារជាតិនៃកម្ពុជា ដោយកម្មវិធីជំនួយបច្ចេកទេសទាំងនេះបានចូលរួមចំណែកក្នុងការកសាងសមត្ថភាពមន្ត្រីជំនាញ ក៏ដូចជាផ្តល់ជាធាតុចូលសំខាន់ៗក្នុងការកំណត់គោលនយោបាយសំដៅអភិវឌ្ឍនិងពង្រឹងស្ថិរភាពវិស័យហិរញ្ញវត្ថុនៅកម្ពុជាផងដែរ។









## លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមកិច្ចប្រជុំជាមួយគណៈប្រតិភូនៃក្រុមប្រឹក្សាធុរកិច្ចអាមេរិក-អាស៊ាន (US-ABC)

ថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១



នៅថ្ងៃពុធ ១០រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៧ ខែមេសា ឆ្នាំ២០២១ លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានចូលរួមកិច្ចប្រជុំតាមរយៈប្រព័ន្ធអនឡាញ ជាមួយគណៈប្រតិភូនៃក្រុមប្រឹក្សាធុរកិច្ចអាមេរិក-អាស៊ាន (US-ABC) ដឹកនាំដោយ លោក Alexander C. Feldman ប្រធាន និងជានាយកប្រតិបត្តិនៃក្រុមប្រឹក្សាធុរកិច្ចអាមេរិក-អាស៊ាន។ កិច្ចប្រជុំនេះធ្វើឡើងក្នុងគោលបំណងពិភាក្សាអំពីប្រធានបទសំខាន់ៗ រួមមានដូចជា ៖ i/-ហិរញ្ញវត្ថុតាមបែបឌីជីថល ii/-បរិយាបន្នហិរញ្ញវត្ថុ iii/-ប្រព័ន្ធសុវត្ថិភាពបច្ចេកវិទ្យា iv/-ការផ្តល់ហិញ្ញប្បទានប្រកបដោយចីរភាព និង v/-ការពង្រឹងចំណេះដឹងផ្នែកហិរញ្ញវត្ថុ។ ក្រុមប្រឹក្សាធុរកិច្ចអាមេរិក-អាស៊ាន ក៏បានលើកឡើងអំពីកិច្ចសហប្រតិបត្តិការ និងការរួមចំណែករបស់បណ្តាក្រុមហ៊ុនអាមេរិក ក្នុងការចូលរួមអភិវឌ្ឍន៍និងទំនើបកម្មវិស័យហិរញ្ញវត្ថុនិងធនាគារនៅកម្ពុជា ព្រមទាំងបានលើកឡើងនូវការគាំទ្ររបស់ក្រុមប្រឹក្សាធុរកិច្ចអាមេរិក-អាស៊ានចំពោះការត្រៀមខ្លួនរបស់កម្ពុជាក្នុងការធ្វើជាម្ចាស់ផ្ទះអាស៊ានឆ្នាំ២០២២ខាងមុខ។ ឆ្លៀតក្នុងឱកាសនោះ លោកជំទាវ បានថ្លែងអំណរគុណចំពោះ ក្រុមប្រឹក្សាធុរកិច្ចអាមេរិក-អាស៊ាន និងបណ្តាក្រុមហ៊ុននានារបស់អាមេរិក ដែលបានចូលរួមក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុនៅកម្ពុជា ព្រមទាំងត្រៀមខ្លួនពង្រីកកិច្ចសហប្រតិបត្តិការជាមួយសហរដ្ឋអាមេរិក សំដៅធ្វើទំនើបកម្មវិស័យហិរញ្ញវត្ថុនៅកម្ពុជាឱ្យកាន់តែរីកចម្រើនប្រកបដោយចីរភាពនាពេលអនាគត។





# លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមកិច្ចប្រជុំជាន់ខ្ពស់ ក្នុងអំឡុងកិច្ចប្រជុំនាទិយរដូវប្រចាំឆ្នាំ២០២១ របស់មូលធិនិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក តាមរយៈប្រព័ន្ធអនឡាញ

ថ្ងៃទី៨ ខែមេសា ឆ្នាំ២០២១



នៅព្រឹកថ្ងៃព្រហស្បតិ៍ ១១រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៨ ខែមេសា ឆ្នាំ២០២១ លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានចូលរួមកិច្ចប្រជុំជាន់ខ្ពស់ ដែលរៀបចំដោយនាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិកនៃមូលនិធិរូបិយវត្ថុអន្តរជាតិ ក្នុងអំឡុងកិច្ចប្រជុំនាទិយរដូវប្រចាំឆ្នាំ២០២១ របស់មូលធិនិរូបិយវត្ថុអន្តរជាតិ និងធនាគារពិភពលោក តាមរយៈប្រព័ន្ធអនឡាញ។ កិច្ចប្រជុំនេះត្រូវបានរៀបចំឡើងជារៀងរាល់ឆ្នាំ ក្នុងគោលបំណងផ្តល់ឱកាសដល់តំណាងប្រទេសសមាជិកនៅតំបន់អាស៊ីប៉ាស៊ីហ្វិក អាចពិភាក្សា និងផ្លាស់ប្តូរយោបល់ពាក់ព័ន្ធនិងទស្សនវិស័យសេដ្ឋកិច្ចក្នុងតំបន់។ មូលនិធិរូបិយវត្ថុអន្តរជាតិ បានព្យាករថា សេដ្ឋកិច្ចក្នុងតំបន់អាស៊ីនឹងមានភាពប្រសើរឡើងវិញ ដោយកំណើននឹងកើនពី -១,៥% នៅឆ្នាំ២០២០ ដល់ ៧,៦% នៅឆ្នាំ២០២១ ដោយសារកំណើនតម្រូវការប្រើប្រាស់និងការវិនិយោគក្នុងវិស័យឯកជន ក្នុងនោះ សេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករថានឹងកើនពី -៣,៥% នៅឆ្នាំ២០២០ ដល់ ៤,២% នៅឆ្នាំ២០២១។ ដូចបណ្តាប្រទេសនានាជុំវិញពិភពលោកដែរ សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០២០ បានជួបប្រទះនូវកំណើនអវិជ្ជមានដោយសារឥទ្ធិពលនៃវិបត្តិជំងឺកូវីដ-១៩។ ទោះយ៉ាងណា អត្រាអតិផរណាកម្ពុជាស្ថិតក្នុងកម្រិតទាបប្រមាណ ២,៩% អត្រាប្តូរប្រាក់ប្រែប្រួលក្នុងកម្រិតទាបជាង ១% ស្របពេលដែលទុនបម្រុងអន្តរជាតិត្រូវបានគរពូនជាលំដាប់ ដែលអាចធានាការនាំចូលទំនិញនិងសេវាបាន ១១ខែ ដែលរួមចំណែកក្នុងការរក្សាស្ថិរភាពថ្លៃនិងតុល្យភាពម៉ាក្រូសេដ្ឋកិច្ច។





# លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាយោបល់ក្នុងតំបន់អាស៊ី (FSB RCG Asia) តាមរយៈប្រព័ន្ធអនឡាញ

ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១



កាលពីថ្ងៃអង្គារ ៧កើត ខែជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១ លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាយោបល់ក្នុងតំបន់អាស៊ី (FSB RCG Asia) តាមរយៈប្រព័ន្ធអនឡាញ។ កិច្ចប្រជុំនេះមានគោលបំណងពិភាក្សាអំពីភាពងាយរងគ្រោះនានាដែលអាចមានឥទ្ធិពលលើស្ថិរភាពហិរញ្ញវត្ថុ និងគំនិតផ្តួចផ្តើមថ្មីៗដើម្បីពង្រឹងស្ថិរភាពហិរញ្ញវត្ថុ និងដឹកនាំដោយ ឯកឧត្តម Benjamin E. Diokno ទេសាភិបាលធនាគារកណ្តាលហ្វីលីពីន និងឯកឧត្តម M. Rajeshwar Rao ទេសាភិបាលរងធនាគារកណ្តាលឥណ្ឌា ជាសហប្រធាន និងមានសមាសភាពចូលរួមពីធនាគារកណ្តាល និងអាជ្ញាធរហិរញ្ញវត្ថុក្នុងតំបន់ចំនួន ១៦ ប្រទេស។ កិច្ចប្រជុំបានពិភាក្សាពីស្ថានភាពសេដ្ឋកិច្ចពិភពលោក និងតំបន់ ព្រមទាំងការវិវត្តនៅក្នុងទីផ្សារហិរញ្ញវត្ថុរួមមាន ហានិភ័យលើស្ថិរភាពហិរញ្ញវត្ថុដែលអាចរងផលប៉ះពាល់ពីការរីករាលដាលនៃជំងឺកូវីដ-១៩ និងបញ្ហាប្រឈមនានាក្នុងការស្តារសេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិ និងគោល-នយោបាយគាំទ្រសម្រាប់អាជីវកម្ម។ ទន្ទឹមនេះ កិច្ចប្រជុំក៏បានពិភាក្សាលើបញ្ហាប្រឈមក្នុងការអនុវត្តបទប្បញ្ញត្តិ និងការត្រួតពិនិត្យធនាគារក្នុងអំឡុងពេលវិបត្តិកូវីដ-១៩ រួមមានការផ្លាស់ប្តូរសេណារីយ៉ូក្នុងការធ្វើស្ត្រេសតេស្ត ឱ្យស្របតាមស្ថានភាពបច្ចុប្បន្ន ដើម្បីតាមដាន និងការពារភាពធន់នៃប្រព័ន្ធហិរញ្ញវត្ថុ។





# លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមសិក្ខាសាលាតាមរយៈប្រព័ន្ធអនឡាញស្តីពី "ការត្រួតពិនិត្យផ្អែកលើហានិភ័យ Pillar 2"

**ថ្ងៃទី១៨ ខែឧសភា ដល់ ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២១**



នៅថ្ងៃអង្គារ ៧កើត ដល់ ថ្ងៃពុធ ៧រោច ខែជេស្ឋ ឆ្នាំឆ្លូវ ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៨ ខែឧសភា ដល់ ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២១ លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា រួមជាមួយ លោកជំនាញការ Didier Debals និងមន្ត្រីជំនាញ ចំនួន ២០ រូប បានចូលរួមសិក្ខាសាលាតាមរយៈប្រព័ន្ធអនឡាញ ស្តីពី "ការត្រួតពិនិត្យផ្អែកលើហានិភ័យ Pillar 2" ក្រោមជំនួយបច្ចេកទេសពីមជ្ឈមណ្ឌលស៊ាសិន។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងជាបីវគ្គ ដែលក្នុងមួយវគ្គមានរយៈពេល ២ថ្ងៃ ក្នុងគោលបំណងពិភាក្សា និងចែករំលែកចំណេះដឹងអំពីប្រធានបទសំខាន់ៗ រួមមានដូចជា ៖ i/-សារតារ និងលក្ខណៈស្រដៀងគ្នានៃ Pillar 2 និងការត្រួតពិនិត្យផ្អែកលើហានិភ័យ ii/-ការរៀបចំទម្រង់វិភាគហានិភ័យដោយប្រើវិធីសាស្ត្រ SREP នៅប្រទេសកម្ពុជា iii/-ការវិភាគលើម៉ូឌែលអាជីវកម្ម iv/-ការវាយតម្លៃលើសន្ទនីយភាព v/-ការវាយតម្លៃលើដើមទុន និង vi/-ការផ្តល់ចំណាត់ថ្នាក់លើការវិភាគលើស្ថានភាពរួមរបស់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។ ទន្ទឹមនេះ មជ្ឈមណ្ឌលស៊ាសិន សន្យានឹងផ្តល់ជំនួយបច្ចេកទេសតាមរយៈការរៀបចំសិក្ខាសាលាបន្ថែមទៀត ដើម្បីឱ្យការត្រួតពិនិត្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជាកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត។ ឆ្លៀតក្នុងឱកាសនោះ លោកជំទាវ បានថ្លែងអំណរគុណចំពោះមជ្ឈមណ្ឌលស៊ាសិន ដែលតែងផ្តល់ជាជំនួយបច្ចេកទេសដល់ធនាគារជាតិនៃកម្ពុជា និងចូលរួមក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុនៅកម្ពុជាឱ្យបានកាន់តែរីកចម្រើន។









## លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានដឹកនាំមន្ត្រីជំនាញ ចូលរួមសិក្ខាសាលាស្តីពី "ទំនើបកម្មក្របខ័ណ្ឌគោលនយោបាយរូបិយវត្ថុប្រទេសកម្ពុជា ឡាវ និងវៀតណាម"

ថ្ងៃទី១៤-១៦ ខែមិថុនា ឆ្នាំ២០២១



នៅថ្ងៃចន្ទ ៥កើត ដល់ ថ្ងៃពុធ ៧កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៤-១៦ ខែមិថុនា ឆ្នាំ២០២១ លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា តំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម ទេសាភិបាល បានដឹកនាំមន្ត្រីជំនាញ ចូលរួមសិក្ខាសាលាស្តីពី "ទំនើបកម្មក្របខ័ណ្ឌគោលនយោបាយរូបិយវត្ថុប្រទេសកម្ពុជា ឡាវ និងវៀតណាម" របស់មូលនិធិរូបិយវត្ថុអន្តរជាតិ (CDOT) ប្រចាំនៅប្រទេសថៃ សហការជាមួយនាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិកនៃមូលនិធិរូបិយវត្ថុអន្តរជាតិ តាមរយៈប្រព័ន្ធអនឡាញ។ សិក្ខាសាលានេះត្រូវបានធ្វើឡើងក្នុងគោលបំណងពិភាក្សានិងចែករំលែកបទពិសោធន៍ លើការប្រែប្រួលក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុក្នុងអំឡុងពេល នៃការរីករាលដាលជំងឺកូវីដ-១៩ និងបញ្ហាប្រឈម ដែលធ្វើឱ្យមានផលប៉ះពាល់ដល់ការអនុវត្តក្របខ័ណ្ឌ គោលនយោបាយរូបិយវត្ថុ ព្រមទាំងកាលានុវត្តភាព និងបញ្ហាប្រឈមនៃការធ្វើទំនើបកម្មក្របខ័ណ្ឌគោល នយោបាយរូបិយវត្ថុសម្រាប់ប្រទេសកម្ពុជា ឡាវ និងវៀតណាម ផងដែរ។ សិក្ខាសាលានេះក៏មាន ការចូលពីសេដ្ឋវិទូរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ អ្នកស្រាវជ្រាវសេដ្ឋកិច្ច មន្ត្រីជាន់ខ្ពស់ និងមន្ត្រីជំនាញផ្នែក គោលនយោបាយរូបិយវត្ថុនៃប្រទេស ថៃ ឡាវ វៀតណាម បង់ក្លាដេស និងកូរ៉េ ដើម្បីធ្វើបទបង្ហាញចែករំលែកចំណេះដឹងបទពិសោធន៍និងពិភាក្សាអំពីការធ្វើឱ្យកាន់តែល្អប្រសើរឡើងនូវក្របខ័ណ្ឌគោលនយោបាយរូបិយវត្ថុ។ នាឱកាសនោះ លោកជំទាវ ទេសាភិបាលរង ត្រូវបានអញ្ជើញជាវាគ្មិន ក្នុងកិច្ចប្រជុំតុមូលដើម្បីចែករំលែកបទពិសោធន៍របស់ធនាគារជាតិនៃកម្ពុជាក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ។ លោកជំទាវ បានផ្លាស់ប្តូរមតិយោបល់អំពីឥទ្ធិពលនៃការធ្វើទំនើបកម្មគោលនយោបាយរូបិយវត្ថុ ក្នុងគោលបំណងរក្សាស្ថិរភាពថ្លៃកសាងជំនឿទុកចិត្តមកលើរូបិយវត្ថុ និងរក្សាស្ថិរភាពហិរញ្ញវត្ថុ។





# លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានអនុញ្ញាតឱ្យនាយកការិយាល័យតំណាងពាណិជ្ជកម្មធនាគារ ស៊ូមីតូម៉ូ មីតស៊ុយ ប៊ែងឃីង ខបភើរេសិន ចូលជួបសម្តែងការគួរសម និងជម្រាបជូនពីស្ថានភាពនិងទិសដៅអនាគតរបស់ការិយាល័យតំណាង

ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២១



នៅថ្ងៃអង្គារ ១៣កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២១ លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានអនុញ្ញាតឱ្យលោក Izumi Tanaka នាយកការិយាល័យតំណាងពាណិជ្ជកម្មធនាគារ ស៊ូមីតូម៉ូ មីតស៊ុយ ប៊ែងឃីង ខបភើរេសិន ចូលជួបសម្តែងការគួរសម និងជម្រាបជូនពីស្ថានភាពនិងទិសដៅអនាគតរបស់ការិយាល័យតំណាង នៅក្នុងឱកាសដែលលោកត្រូវបានតែងតាំងជានាយកថ្មី នៃការិយាល័យតំណាងពាណិជ្ជកម្មរបស់ធនាគារ ប្រចាំប្រទេសកម្ពុជា។ លោកជំទាវ ទេសាភិបាលរង បានសម្តែងការស្វាគមន៍ចំពោះលោក ដែលត្រូវមកបំពេញតួនាទីថ្មី ប្រចាំប្រទេសកម្ពុជា នាពេលនេះ ហើយក៏បានបញ្ជាក់ថា ធនាគារជាតិនៃកម្ពុជាគាំទ្រយ៉ាងខ្លាំងចំពោះការចូលរួមរបស់វិនិយោគិនបរទេសចំពោះការអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា។ តាមរយៈតួនាទីរបស់ការិយាល័យតំណាង លោកជំទាវ បានស្នើឱ្យមានការផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់វិនិយោគិនជប៉ុនពីការអភិវឌ្ឍនិងការរីកចម្រើនរបស់សង្គមនិងសេដ្ឋកិច្ចកម្ពុជា ជាពិសេស កត្តាសន្តិភាពដែលជាមូលដ្ឋានអំណោយផលដល់ការវិនិយោគ។ ជាការឆ្លើយតប លោក Izumi Tanaka បានថ្លែងអំណរគុណចំពោះការស្វាគមន៍យ៉ាងកក់ក្តៅពីធនាគារជាតិនៃកម្ពុជា និងបានជម្រាបជូនថា ការិយាល័យតំណាងពាណិជ្ជកម្មធនាគារ SMBC មានតួនាទីផ្តល់ការសម្របសម្រួលខាងផ្នែកពាណិជ្ជកម្ម និងលំហូរវិនិយោគរវាងប្រទេសកម្ពុជា និងប្រទេសជប៉ុន តំបន់អាស៊ី និងតំបន់ផ្សេងៗ។ ដូច្នេះ នៅក្នុងតួនាទីថ្មីនេះ លោកនឹងខិតខំផ្សព្វផ្សាយពីឱកាសវិនិយោគនៅកម្ពុជាដល់វិនិយោគិនជប៉ុន និងចែករំលែកចំណេះដឹងនិងបទពិសោធន៍ចំពោះវិស័យធនាគារនៅកម្ពុជា ជាពិសេសផ្តោតលើហិរញ្ញវត្ថុបៃតង។





# លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមក្នុងសន្និសីទជាន់ខ្ពស់តាមរយៈប្រព័ន្ធអនឡាញ ដែលសហការរៀបចំដោយ វិទ្យាស្ថានស្ថិរភាពហិរញ្ញវត្ថុ (FSI) ធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) និងធនាគារកណ្តាលនៃប្រទេសបាហាម៉ាស់ (Bahamas)

ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១



នៅថ្ងៃពុធ ៦រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ លោកជំទាវ នាវ ច័ន្ទថាណា ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានចូលរួមក្នុងសន្និសីទជាន់ខ្ពស់តាមរយៈប្រព័ន្ធអនឡាញ ដែលសហការ រៀបចំដោយ វិទ្យាស្ថានស្ថិរភាពហិរញ្ញវត្ថុ (FSI) ធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) និងធនាគារកណ្តាលនៃប្រទេសបាហាម៉ាស់ (Bahamas)។ សន្និសីទនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងពិភាក្សាលើបញ្ហាប្រឈមក្នុងការអនុវត្តតាមស្តង់ដាបាសែល ជាពិសេសបញ្ហាប្រឈមនៃការត្រួតពិនិត្យក្នុងប្រទេសតូចៗដែលមិនមែនជា សមាជិកគណៈកម្មការទីក្រុងបាសែល។ ក្នុងសន្និសីទនេះ លោកជំទាវ ទេសាភិបាលរង ក៏ត្រូវបានអញ្ជើញឱ្យចូលរួមធ្វើជាវាគ្មិន ក្នុងកិច្ចពិភាក្សានិងការចែករំលែកបទពិសោធន៍របស់ធនាគារជាតិ នៃកម្ពុជាអំពីការអនុត្តតាមស្តង់ដា បាសែលក្នុងការត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ការប្រឈម និងដំណោះស្រាយក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យនៃប្រទេសតូចក្នុងតំបន់។





## លោកជំទាវ អ៊ុក ម៉ាលី ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំគណៈកម្មការគោលនយោបាយ (Policy Committee) ស្តីពីការអនុវត្តកម្មវិធីឆ្លើយតបនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ និងការស្តារសម្បទាសេដ្ឋកិច្ចឡើងវិញ (COVID-19 Active Response and Expenditure Support Program- CARES)

ថ្ងៃទី៩ ខែមេសា ឆ្នាំ២០២១



កាលពីថ្ងៃសុក្រ ១២រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៩ ខែមេសា ឆ្នាំ២០២១ លោកជំទាវ អ៊ុក ម៉ាលី ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំគណៈកម្មការគោលនយោបាយ (Policy Committee) តាមរយៈប្រព័ន្ធអនឡាញ ស្តីពីការអនុវត្តកម្មវិធីឆ្លើយតបនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ និងការស្តារសម្បទាសេដ្ឋកិច្ចឡើងវិញ (COVID-19 Active Response and Expenditure Support Program- CARES)។ កិច្ចប្រជុំនេះ ត្រូវបានសហការរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ក្នុងគោលបំណងតាមដានវឌ្ឍនភាពនិងពិភាក្សាលើរបាយការណ៍ប្រចាំត្រីមាសលើកទី២ សម្រាប់ខែតុលា-ធ្នូ ២០២០ នៃការអនុវត្តកម្មវិធី CARES។ កម្មវិធី CARES គឺជាកិច្ចព្រមព្រៀងឥណទានសម្បទានរវាងរាជរដ្ឋាភិបាលកម្ពុជា និង ADB។ កម្មវិធីនេះបានចែកជាសសរស្តម្ភ ៣ រួមមាន៖ i/- វិធានការសុខភាពដើម្បីប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ ii/- ជំនួយសង្គមដើម្បីបង្ការការកើនឡើងនៃភាពក្រីក្រ និង iii/- ការគាំទ្រដល់ការងើបឡើងវិញនៃសេដ្ឋកិច្ច (រួមមាន ឧបត្ថម្ភធនប្រាក់ឈ្នួលដល់កម្មកររោងចក្រ និងបុគ្គលិកវិស័យទេសចរណ៍, កម្ចីគាំទ្រដល់សហគ្រាសធុនតូច និងមធ្យម, ការបណ្តុះបណ្តាលជំនាញ និងសេវាកម្មការងារ)។ សម្រាប់ឆ្នាំ២០២០ កន្លងមក ធនាគារអភិវឌ្ឍន៍អាស៊ី បានកោតសរសើរ ចំពោះរាជរដ្ឋាភិបាលកម្ពុជា និងភាគីពាក់ព័ន្ធ ក្នុងការខិតខំសម្រេចឱ្យបានទៅតាមសូចនាករដែលបានកំណត់ក្នុងកម្មវិធី CARES នេះ។





## លោកជំទាវ អ៊ុក ម៉ាលី ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមកិច្ចប្រជុំលើកទី១ គណៈកម្មា-ធិការជាតិជំរឿនសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២១

ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១



នៅព្រឹកថ្ងៃចន្ទ ៥កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២១ លោកជំទាវ អ៊ុក ម៉ាលី ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា អញ្ជើញចូលរួមកិច្ចប្រជុំលើកទី១ គណៈកម្មាធិការជាតិជំរឿនសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២១ ស្តីពីដំណើរការអនុវត្តគម្រោងការងារ ជំរឿនសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២១-២០២៣ ដែលរៀបចំឡើងដោយ ក្រសួងផែនការ និងមានការចូលរួមពីសមាជិក សមាជិកា នៃគណៈកម្មាធិការជាតិជំរឿនសេដ្ឋកិច្ច។ កិច្ចប្រជុំនេះមានគោលបំណងពិភាក្សាស្វែងរកធាតុចូល និងពិនិត្យនិងសម្រេចលើខ្លឹមសារនៃឯកសារពាក់ព័ន្ធនឹងដំណើរការជំរឿនសេដ្ឋកិច្ច នៅព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០២១-២០២៣។ អង្គប្រជុំបានឯកភាពលើ ៣ចំណុច រួមមាន៖ i/-គម្រោងផែនការអនុវត្តសកម្មភាព ii/-ស្លាកសញ្ញា (Logo) និង iii/-កំណត់កាលបរិច្ឆេទយោងជំរឿន ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២។



## ឯកឧត្តម ស៊ុំ សន្និសិទ្ធ ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមកិច្ចប្រជុំគោលនយោបាយស៊ាសិនប្រចាំឆ្នាំ២០២១ ក្រោមប្រធានបទស្ដីពី "បញ្ហាប្រឈម និងជម្រើសក្នុងការគ្រប់គ្រងលំហូរមូលធនសម្រាប់ប្រទេសដែលមានសេដ្ឋកិច្ចតូច បើកទូលាយ និងមានសមាហរណកម្មវិស័យហិរញ្ញវត្ថុ"

**ថ្ងៃទី២២-២៣ ខែមេសា ឆ្នាំ២០២១**




កាលពីថ្ងៃព្រហស្បតិ៍ ១១កើត និងថ្ងៃសុក្រ ១២កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២២-២៣ ខែមេសា ឆ្នាំ២០២១ ឯកឧត្តម ស៊ុំ សន្និសិទ្ធ ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានចូលរួមកិច្ចប្រជុំគោលនយោបាយស៊ាសិនប្រចាំឆ្នាំ២០២១ ក្រោមប្រធានបទស្ដីពី "បញ្ហាប្រឈម និងជម្រើសក្នុងការគ្រប់គ្រងលំហូរមូលធនសម្រាប់ប្រទេសដែលមានសេដ្ឋកិច្ចតូច បើកទូលាយ និងមានសមាហរណកម្មវិស័យហិរញ្ញវត្ថុ" តាមរយៈប្រព័ន្ធអនឡាញ។ កិច្ចប្រជុំនេះត្រូវបានរៀបចំឡើងដើម្បីវិភាគលើបញ្ហាប្រឈមដែលកើតមានឡើងក្នុងការវិវត្តនិងបម្រែបម្រួលនៃលំហូរមូលធន និងផ្តល់ជាទស្សនវិស័យសម្រាប់គោលនយោបាយ ដែលទាក់ទងនឹងការបង្កើនភាពធន់ក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាពិសេស ការរួមបញ្ចូលគ្នារវាងគោលនយោបាយរូបិយវត្ថុ ការប្តូរប្រាក់ ម៉ាក្រូប្រុងប្រយ័ត្ន និងការគ្រប់គ្រងលំហូរមូលធន ក្នុងទិសដៅរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩។ កិច្ចប្រជុំនេះ ក៏មានការចូលរួមពីវាគ្មិនមកពីធនាគារកណ្តាល សាកលវិទ្យាល័យ និងស្ថាប័នអន្តរជាតិនានាផងដែរ។



# ឯកឧត្តម ស៊ុំ សន្និសិទ្ធ ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមសិក្ខាសាលាស្តីពី ការប្រែប្រួលអាកាសធាតុ និងហានិភ័យអធិបតេយ្យភាព

ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២១




នៅថ្ងៃពុធ ៩រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២១ ឯកឧត្តម ស៊ុំ សន្និសិទ្ធ ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមសិក្ខាសាលាស្តីពី ការប្រែប្រួលអាកាសធាតុ និងហានិភ័យអធិបតេយ្យភាព ដែលរៀបចំដោយវិទ្យាស្ថានធនាគារអភិវឌ្ឍន៍អាស៊ី តាមរយៈប្រព័ន្ធអនឡាញ។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងជាកម្មវិធីបន្ថែមទៅលើកិច្ចប្រជុំមហាសន្និបាតប្រចាំឆ្នាំលើកទី៥៤ របស់ធនាគារអភិវឌ្ឍន៍អាស៊ី ក្នុងគោលបំណងពិភាក្សាអំពីបញ្ហាប្រឈម និងដំណោះស្រាយលើបញ្ហាបម្រែបម្រួលអាកាសធាតុ ក្នុងបរិបទដែលសេដ្ឋកិច្ចសកលកំពុងទទួលរងផលប៉ះពាល់បន្ថែមពីការរីករាលដាលជំងឺកូវីដ-១៩ ក៏ដូចជាការបង្កជាបន្ទុកបន្ថែមមួយកម្រិតទៀតសម្រាប់ការរៀបចំថវិការដ្ឋនិងស្ថិរភាពហិរញ្ញវត្ថុ។ អាស៊ីអាគ្នេយ៍ជាតំបន់មួយដែលងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុបំផុតនៅលើពិភពលោក ក្នុងនោះមីយ៉ាន់ម៉ា ហ្វីលីពីន វៀតណាម ថៃ និងកម្ពុជា កំពុងទទួលរងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ដែលនឹងមានឥទ្ធិពលដល់ពាណិជ្ជកម្មអន្តរជាតិ ផលិតកម្ម ការងារ និងហិរញ្ញប្បទានរដ្ឋាភិបាល។ នៅពេលភាពងាយរងគ្រោះនៃហានិភ័យអាកាសធាតុកាន់តែខ្ពស់ នាំឱ្យថ្លៃដើមការខ្ចីរដ្ឋាភិបាលកើនឡើងគួរឱ្យកត់-សម្គាល់។ ធនាគារជាតិនៃកម្ពុជាបានបញ្ចូលគោលការណ៍អភិបាលកិច្ចសង្គមបរិស្ថាន (ESG) ទៅក្នុងសេចក្តីណែនាំលើការវិនិយោគទុនបម្រុងអន្តរជាតិ ដោយមិនធ្វើការវិនិយោគទៅលើទ្រព្យសកម្មដែលប៉ះពាល់ដល់បរិស្ថាន ព្រមទាំងបង្កើនការវិនិយោគទៅលើសញ្ញាប័ណ្ណបៃតងផងដែរ។ នៅឆ្នាំ២០១៩ ធនាគារជាតិនៃកម្ពុជាបានក្លាយជាវិនិយោគិនមួយក្នុងចំណោមវិនិយោគិនដំបូងដែលវិនិយោគលើមូលនិធិសញ្ញាប័ណ្ណបៃតងរបស់ធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) ដើម្បីបង្ហាញពីឆន្ទៈប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ។



## ឯកឧត្តម ស៊ុំ សន្និសិទ្ធ ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ២០២១ លើកទី៩១ របស់ធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) តាមរយៈប្រព័ន្ធអនឡាញ

ថ្ងៃទី២៨-២៩ ខែមិថុនា ឆ្នាំ២០២១




កាលពីថ្ងៃចន្ទ ៤រោច ដល់ថ្ងៃអង្គារ ៥រោច ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៨-២៩ ខែមិថុនា ឆ្នាំ២០២១ ឯកឧត្តម ស៊ុំ សន្និសិទ្ធ ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជា តំណាងដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម ទេសាភិបាល បានចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ២០២១ លើកទី៩១ របស់ធនាគារសម្រាប់ការទូទាត់អន្តរជាតិ (BIS) តាមរយៈប្រព័ន្ធអនឡាញ។ កិច្ចប្រជុំនេះត្រូវបានធ្វើឡើងក្នុងគោលបំណងចែករំលែកពីប្រធានបទថ្មីៗមួយចំនួន ទាក់ទងអំពី i/-បញ្ហាប្រឈមរបស់ធនាគារកណ្តាលក្រោយការរីករាលដាលនៃជំងឺកូវីដ-១៩ ii/-ដំណើរវិវត្តនៃការអនុវត្តគោលនយោបាយរូបិយវត្ថុ (The Distributional Footprint of Monetary Policy) និង iii/-រូបិយវត្ថុឌីជីថលរបស់ធនាគារកណ្តាល (CBDC)។





## ធនាគារជាតិនៃកម្ពុជាបានបើកយុទ្ធនាការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនដល់មន្ត្រីបុគ្គលិក, បុគ្គលិកកិច្ចសន្យា និងបុគ្គលិកអណ្ដែតសរុបប្រមាណ ៨០០នាក់ នៅមន្ទីរពេទ្យកុមារ

ថ្ងៃទី៩ ខែមេសា ឆ្នាំ២០២១



នៅថ្ងៃសុក្រ ១២រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៩ ខែមេសា ឆ្នាំ២០២១ ធនាគារជាតិនៃកម្ពុជាបានបើកយុទ្ធនាការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនដល់មន្ត្រីបុគ្គលិក, បុគ្គលិកកិច្ចសន្យា និងបុគ្គលិកអណ្ដែតសរុបប្រមាណ ៨០០នាក់ នៅមន្ទីរពេទ្យកុមារជាតិ ចាប់ពីថ្ងៃទី៩ ដល់ថ្ងៃទី១១ ខែមេសា ឆ្នាំ២០២១។ ការចាក់វ៉ាក់សាំងកូវីដ-១៩ គឺជាកិច្ចការដ៏សំខាន់របស់មន្ត្រីបុគ្គលិកគ្រប់រូប ដើម្បីចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការបង្ការ និងទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ជាសហគមន៍ និងរួមចំណែកដល់ការស្ដារឡើងវិញនៃសកម្មភាពសេដ្ឋកិច្ចនិងកំណើនសេដ្ឋកិច្ច។ គួររំលឹកដែរថា បើទោះជាបុគ្គលម្នាក់ៗបានទទួលវ៉ាក់សាំងរួចក៏ដោយ ក៏ត្រូវតែបន្តចូលរួមអនុវត្តវិធានការសុខាភិបាល ដោយអនុវត្តវិធានការ ៣ការពារ (ពាក់ម៉ាក់, លាងដៃញឹកញាប់ និងរក្សាគម្លាតសុវត្ថិភាព) និង៣កុំ (កុំទៅកន្លែងមានមនុស្សកុះករច្រើន, កុំទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល និងកុំប៉ះពាល់គ្នា)។










## លោកជំទាវ ជា សិរី ឧបការីទេសាភិបាល និងជាអគ្គនាយកបច្ចេកទេស ធនាគារជាតិនៃកម្ពុជា បានអញ្ជើញជាវាគ្មិនក្នុងកិច្ចពិភាក្សាចែករំលែកបទពិសោធន៍ពាក់ព័ន្ធនឹងប្រព័ន្ធបាគង ដែលជាប្រព័ន្ធទូទាត់សងប្រាក់ជំនាន់ថ្មីរបស់ប្រទេសកម្ពុជា

ថ្ងៃទី១ ខែមេសា ឆ្នាំ២០២១



នៅថ្ងៃព្រហស្បតិ៍ ៤រោច ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១ ខែមេសា ឆ្នាំ២០២១ លោកជំទាវ ជា សិរី ឧបការីទេសាភិបាល និងជាអគ្គនាយកបច្ចេកទេសធនាគារជាតិនៃកម្ពុជា បានអញ្ជើញជាវាគ្មិនក្នុងកិច្ចពិភាក្សាចែករំលែកបទពិសោធន៍ពាក់ព័ន្ធនឹងប្រព័ន្ធបាគង ដែលជាប្រព័ន្ធទូទាត់សងប្រាក់ជំនាន់ថ្មីរបស់ប្រទេសកម្ពុជា ជាមួយមន្ត្រីជាន់ខ្ពស់របស់ធនាគារកណ្តាលប៉ាគីស្ថានតាមរយៈប្រព័ន្ធអនឡាញ។ កិច្ចពិភាក្សានេះ មានការអញ្ជើញចូលរួមពី លោកជំទាវ Sima Kamil ទេសាភិបាលរង ធនាគារកណ្តាលប៉ាគីស្ថាន និងមន្ត្រីជាន់ខ្ពស់ជាច្រើនរូបទៀតមកពីធនាគារកណ្តាលប៉ាគីស្ថានក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការរវាងធនាគារកណ្តាលទាំងពីរក៏ដូចជាផ្លាស់ប្តូរបទពិសោធន៍ក្នុងការអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់បច្ចេកវិទ្យាហិរញ្ញវត្ថុជាពិសេសបទពិសោធន៍ពាក់ព័ន្ធនឹងការអភិវឌ្ឍប្រព័ន្ធបាគង។ ប្រព័ន្ធបាគងដែលបានដាក់ឱ្យដំណើរការជាផ្លូវការកាលពីថ្ងៃទី២៨ខែតុលាឆ្នាំ២០២០គឺជាហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់ស្នូលមួយដែលអាចឱ្យធនាគារសមាជិកនិងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុរបស់ខ្លួនធ្វើប្រតិបត្តិការអន្តរធនាគារប្រកបដោយសុវត្ថិភាពនិងប្រសិទ្ធភាពព្រមទាំងមិនគិតថ្លៃសម្រាប់ការផ្ទេរប្រាក់ក៏ដូចជាកាត់បន្ថយចំណាយប្រតិបត្តិការហើយសំខាន់ជាងនេះទៅទៀតគឺជំរុញបរិយាបន្នហិរញ្ញវត្ថុ។



## លោកជំទាវ ជា សិរី ឧបការីទេសាភិបាល និងជាអគ្គនាយកបច្ចេកទេស ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមជាវាគ្មិនកិត្តិយសក្នុងកិច្ចពិភាក្សាស្តីពី "ហេដ្ឋារចនាសម្ព័ន្ធឌីជីថលគ្រឹះសម្រាប់សេដ្ឋកិច្ចឌីជីថលប្រកបដោយបរិយាបន្ន" ក្នុងកម្មវិធី SFF Green Shoots Series ដែលរៀបចំដោយអាជ្ញាធររូបិយវត្ថុសិង្ហបុរី

ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១




នៅថ្ងៃចន្ទ ១៥កើត ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២១ លោកជំទាវ ជា សិរី ឧបការីទេសាភិបាល និងជាអគ្គនាយកបច្ចេកទេស ធនាគារជាតិនៃកម្ពុជាបានអញ្ជើញចូលរួមជាវាគ្មិនកិត្តិយសក្នុងកិច្ចពិភាក្សាស្តីពី "ហេដ្ឋារចនាសម្ព័ន្ធឌីជីថលគ្រឹះសម្រាប់សេដ្ឋកិច្ចឌីជីថលប្រកបដោយបរិយាបន្ន" ក្នុងកម្មវិធី SFF Green Shoots Series ដែលរៀបចំដោយអាជ្ញាធររូបិយវត្ថុសិង្ហបុរី។ កម្មវិធីនេះមានការចូលរួមពីវាគ្មិនល្បីៗ ដូចជា លោក Ravi Menon នាយកគ្រប់គ្រងអាជ្ញាធររូបិយវត្ថុសិង្ហបុរី លោកស្រី Hajah Rokiah binti Haji Badar នាយកគ្រប់គ្រងអាជ្ញាធររូបិយវត្ថុប្រ៊ុយណេ លោកបណ្ឌិត Patrick Njoroge ទេសាភិបាលធនាគារកណ្តាលកេនយ៉ា និងលោកបណ្ឌិត Maxwell Opoku-Afari ទេសាភិបាលរងទី១ធនាគារកណ្តាលហ្គាណា។ ក្នុងកិច្ចពិភាក្សានោះ លោកជំទាវបានលើកឡើងអំពីការអភិវឌ្ឍនិងសារៈសំខាន់នៃហេដ្ឋារចនាសម្ព័ន្ធឌីជីថល ជាពិសេស ការអភិវឌ្ឍប្រព័ន្ធបាគងក្នុងការលើកកម្ពស់អន្តរប្រតិបត្តិការឆ្លងគ្រឹះស្ថានក្នុងប្រទេសកម្ពុជានិងការផ្ទេរប្រាក់ឆ្លងប្រទេស។ ក្នុងឱកាសនោះដែរ អាជ្ញាធររូបិយវត្ថុសិង្ហបុរីបានចេញផ្សាយជាផ្លូវការនូវឯកសារសិក្សាស្រាវជ្រាវ (White Paper) ស្តីពី "ហេដ្ឋារចនាសម្ព័ន្ធឌីជីថលគ្រឹះសម្រាប់សេដ្ឋកិច្ចឌីជីថលប្រកបដោយបរិយាបន្ន" ដែលជាសមិទ្ធិផលដំបូងនៃការអនុវត្តគម្រោង Global Foundational Stack ផ្តួចផ្តើមដោយអាជ្ញាធររូបិយវត្ថុសិង្ហបុរី និងមានការចូលរួមពីធនាគារជាតិនៃកម្ពុជា អាជ្ញាធររូបិយវត្ថុប្រទេសប្រ៊ុយណេ ធនាគារកណ្តាលប្រទេសកេនយ៉ា និងធនាគារកណ្តាលប្រទេសហ្គាណា ហើយករណីសិក្សាអំពីហេដ្ឋារចនាសម្ព័ន្ធឌីជីថលប្រទេសកម្ពុជាក៏ត្រូវបានដាក់បញ្ចូលជាផ្នែកមួយក្នុងឯកសារសិក្សាស្រាវជ្រាវនេះដែរ។






## លោកជំទាវ ជា សិរី ឧបការីទេសាភិបាលនិងជាអគ្គនាយកបច្ចេកទេស ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមប្រជុំតាមប្រព័ន្ធអនឡាញជាមួយក្រុមហ៊ុន Moody's ដែលដឹកនាំដោយលោក James Flitton ប្រធានគ្រប់គ្រងទំនាក់ទំនងនៅតំបន់អាស៊ានប្រចាំនៅប្រទេសសិង្ហបុរី

ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១

កាលពីថ្ងៃអង្គារ ១រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ លោកជំទាវ ជា សិរី ឧបការីទេសាភិបាលនិងជាអគ្គនាយកបច្ចេកទេស ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមប្រជុំតាមប្រព័ន្ធអនឡាញជាមួយក្រុមហ៊ុន Moody's ដែលដឹកនាំដោយលោក James Flitton ប្រធានគ្រប់គ្រងទំនាក់ទំនងនៅតំបន់អាស៊ានប្រចាំនៅប្រទេសសិង្ហបុរី ក្នុងគោលបំណងពិភាក្សានិងផ្លាស់ប្ដូរយោបល់សម្រាប់ប្រធានបទ៖ i/-ការណែនាំក្រុមការងាររបស់ក្រុមហ៊ុន Moody's ផ្នែកទំនាក់ទំនង ii/-ការពិភាក្សាលើប្រធានបទ បរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) និង iii/- ហិរញ្ញវត្ថុប្រកបដោយចីរភាព (sustainable finance)។ឆ្លៀតក្នុងឱកាសនោះ លោកជំទាវ ជា សិរី បានសំណូមពរដល់ក្រុមហ៊ុន Moody's ចែករំលែកចំណេះដឹងនិងបទពិសោធន៍ដល់មន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជា និងសមាជិកសមាគមធនាគារនៅកម្ពុជាទាក់ទងនឹងវិធីសាស្ត្រក្នុងការផ្ដល់ចំណាត់ថ្នាក់លើឥណទាន និងបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG) ដែលនាំឱ្យមានការវិនិយោគប្រកបដោយចីរភាព។



